**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Feb-2012, 15:07
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សារណាឆ្លើយតបចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងបញ្ជីឯកសារដែលត្រូវដាក់ នៅសវនាការលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
ព្រុំ ផល្លា

<u>ផ្ញើជូន</u>៖

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**
**Elisabeth SIMONNEAU-FORT**

# I. សេចក្តីផ្តើម

១. អនុលោមតាមដីកាចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់អង្គជំនុំជម្រះសាលាដំបូង[1] មេធាវីការពារជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារ") សូមដាក់ចម្លើយតបដ៏ខ្លីនេះចំពោះ "ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបញ្ជីឯកសាររបស់ នួន ជា ដែលត្រូវដាក់នៅសវនាការជំនុំជម្រះលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ("ចម្លើយតប")[2]។ ក្រុមមេធាវីការពារក្តីប្រកាន់ជំហរថា នឹងចំណាត់ថ្នាក់ចម្លើយតបនេះជាសាធារណៈ។ នៅគ្រប់ករណីទាំងអស់ក្រុមមេធាវីការពារក្តីចាត់ទុកចម្លើយតបនេះជាសាធារណៈ ។

២. វាត្រូវបានគេកត់សម្គាល់តាំងពីការចាប់ផ្តើមមកថា ខណៈដែលការិយាល័យសហព្រះរាជអាជ្ញា ("កសព") ជំទាស់ទៅនឹងការដាក់ឯកសារជាច្រើនដែលស្នើឡើងដោយក្រុមមេធាវីការពារក្តី "ដោយសារលើកឡើងថា ក្រុមមេធាវីការពារក្តីមិនគោរពដោយ [ចេតនា] តាមការណែនាំលើកមុនៗរបស់អង្គជំនុំជម្រះចំពោះការដាក់បញ្ជីឯកសារស្របតាមវិធាន ៨៧(៣) និងការខកខានរបស់ក្រុមមេធាវីការពារក្តីមិនបំពេញបានវិធាន ៨៧(៤) ទាក់ទងនឹងបញ្ជីឯកសារថ្មីដែលស្នើឡើងដោយក្រុមមេធាវីការពារ[3] ដូច្នេះការទទូចរបស់សហព្រះរាជអាជ្ញាអំពីការគោរពដ៏ម៉ឺងម៉ាត់តាមវិធានផ្ទៃក្នុងរបស់អវតក ("វិធានផ្ទៃក្នុង") គឺមិនមានសារសំខាន់អ្វីទេ ជាមួយនឹងការបញ្ជាក់ជំហរយ៉ាងច្បាស់នៅក្នុងតុលាការដោយសហព្រះរាជអាជ្ញារងអន្តរជាតិ៖

---

[1] សូមមើលពង្រាង "ប្រតិចារិតនៃកិច្ចដំណើរការជំនុំជម្រះក្តី" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១២ នៅទំព័រ 58:24-59 (ប្រធាន: ឥឡូវនេះអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យលោកមេធាវីការពារក្តីដាក់ជាលាយលក្ខណ៍អក្សរនូវចម្លើយតបរបស់ខ្លួន ទាក់ទងនឹងឯកសារពីរចុងក្រោយ ដែលលើកឡើងដោយព្រះរាជអាជ្ញា- ទាក់ទងនឹងឯកសារពីរចុងក្រោយដែលលើកឡើងដោយសហព្រះរាជអាជ្ញា ដែលមិនត្រូវបានបកប្រែ ។ អង្គជំនុំជម្រះសាលាដំបូងចង់បានមតិយោបល់ពីមេធាវីការពារក្តី") ។ ដូចខាងលើនៅទំព័រ 59:13-16 (ចៅក្រម fenz: យើងស្នើឲ្យមានសារណាជាលាយលក្ខណអក្សរទៅនឹងឯកសាររបស់សហព្រះរាជអាជ្ញា ដែលជំទាស់នឹងការទទួលយកបញ្ជីឯកសារដាក់ដោយ នួន ជា នៅខែមករា") ។

[2] ឯកសារ ចុះថ្ងៃទី **E-131/1/14**, ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ , ERN 00778329–00778335.

[3] ចម្លើយតបនៅកថាខណ្ឌទី២ ។

> [យើង] យល់ស្របជាមួយមេធាវីលោក នួន ជា ថាយើងថាតុលាការនេះត្រូវអនុវត្តនូវគោលការជាមូលដ្ឋានដែលតុលាការជាតិក៏បានប្រើ ហើយច្បាប់ក៏តម្រូវឲ្យប្រើដែរ។ ក៏ប៉ុន្តែ តុលាការនេះក៏ត្រូវបង្កើតជាឧទាហរណ៍ជាគំរូក្នុងការអនុវត្តនូវសវនាការដ៏មានប្រសិទ្ធភាព មានយុត្តិធម៌ ការពារផលប្រយោជន៍ជនជាប់ចោទ [...] ហើយធ្វើឲ្យប្រាកដថាយើងមើលភស្តុតាងទាំងអស់ដែលមាន ហើយយើងនឹងទទួលយកនូវគោលការណ៍ទាំងអស់នោះ ដែលដូចគ្នានឹងគោលការណ៍របស់តុលាការជាតិនោះដែរ ហើយវាក៏អាចណែនាំដល់តុលាការជាតិ ជាគំរូមួយសម្រាប់ការវិវត្តន៍នៃការជំនុំជម្រះទៅអនាគត[4]។

ពិតណាស់ការគោរពនីតិវិធីកម្ពុជាដែលនៅជាធរមាន គឺជាជំហរដែលមេធាវីការពារក្តីតែងតែប្រកាន់មកតាំងតែពីការចាប់ផ្តើមករណីនេះមកម្ល៉េះ។ ហើយទាក់ទងនឹងការដាក់បង្ហាញភស្តុតាងជាឯកសារមកទល់នឹងពេលនេះ ក្រុមមេធាវីការពារក្តីមិនដែលមានរឿងជាមួយនឹងបទប្បញ្ញត្តិច្បាប់ជាតិម្តងណាឡើយ ។

៣. ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទប់ស្កាត់ក្រុមមេធាវីការពារក្តីមិនឲ្យបង្កើត និង ពិភាក្សាភស្តុតាងដែលពាក់ព័ន្ធនៅតុលាការ គឺជាការរំលោភច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទក្នុងការអះអាង ឬបង្ហាញករណីរបស់គាត់ ជាការឆ្លើយតបទៅនឹងការអះអាងផ្ទុយ[5] សិទ្ធិក្នុងការអធិប្បាយលើភស្តុតាងទាំងអស់ដោយបញ្ចេញមតិយោបល់នានា ដើម្បីធ្វើឲ្យមានឥទ្ធិពលលើសេចក្តីសម្រេចរបស់តុលាការ គឺជាផ្នែកនៃសិទ្ធិទទួលបានសវនាការដេញដោលចំពោះមុខ និង គោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី[6]។ គោលការណ៍សមភាពនៃមធ្យបាយតទល់ក្តីតម្រូវថា "ភាគីនីមួយៗត្រូវតែមានឱកាសសមហេតុផល ដើម្បីបង្ហាញករណីរបស់ខ្លួននៅក្រោមលក្ខខណ្ឌដែលមិនដាក់ឲ្យគាត់ចាញ់ប្រៀបនឹងគូរបដិបក្សរបស់គាត់"[7]។ ដូច្នេះមេធាវីការពារក្តីត្រូវតែបានផ្តល់ឱកាស

---

[4] ឯកសារ E-1/28.1, ("ប្រតិចារិតនៃសវនាការលើអង្គសេចក្តី" ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១២ (ថ្ងៃសវនាទី១៧)នៅទំព័រ 5:2-12 ។

[5] សូមមើល ឧទាហរណ៍ Harris, O'Boyle, និង Warbrick, ច្បាប់នៃកតិការសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (LAW OF THE EUROPEAN CONVENTION ON HUMAN RIGHTS), 2nd Ed (2009), នៅទំព័រ 253–254 ។

[6] ដូចខាងលើ ។

[7] *De Haas and Gijsels* តទល់ *Belgium*, ECtHR ពាក្យបណ្តឹងលេខ19983/92, "សេចក្តីសម្រេច" ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ នៅកថាខណ្ឌ ៥៣ ។

សមហេតុផលដើម្បីប្រតិកម្មតបទៅនឹងការអធិប្បាយ ឬធ្វើការវាយបកវិញទៅនឹងភស្តុតាងដែលការិយាល័យសហព្រះរាជអាជ្ញាបង្ហាញនៅក្នុងតុលាការ ។

៤. ការដាក់ពេលវេលាកំណត់ដែលមានភាពបត់បែនសម្រាប់ការកំណត់អត្តសញ្ញាណនៃឯកសារភស្តុតាងដែលដាក់ដោយភាគី អាចជាឧបករណ៍ដ៏មានប្រយោជន៍សម្រាប់គ្រប់គ្រងសំណុំរឿង តែពេលវេលាកំណត់បែបនេះ មិនត្រូវប្រើប្រាស់ដើម្បីធ្វើមិនឲ្យសម្រេចនូវសិទ្ធិសារវិជ្ជមានរបស់ជនជាប់ចោទដើម្បីបង្ហាញភស្តុតាងឡើយ។ នេះជាមូលហេតុដែល កសព មានប្រៀប ហើយអង្គជំនុំជម្រះហាក់ដូចជាយល់ស្របហើយដែរ។ តែមធ្យោបាយបែបនេះ បើសិនអនុញ្ញាតឲ្យមានអធិកភាព នឹងមិនមានអ្វីក្រៅពីទម្រង់នៃជ័យជំនះលើសារសំខាន់ដែលបំរើគោលបំណងដែលគ្មានធម្មានុរូបឡើយ។ ទាក់ទងនឹងចំនុចនេះ ឧបសគ្គបន្ថែមដែលដាក់ដោយវិធាន ៨៧(៤) ហើយអង្គជំនុំជម្រះសាលាដំបូងមិនពិចារណាសិទ្ធិសារវិជ្ជមានរបស់ជនជាប់ចោទ ឬអនុវត្តជាក់ស្តែងនៃករណី ០០២ ។ ផ្ទុយទៅវិញ មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវបានពង្រាងយ៉ាងប្រយ័ត្នប្រយែងដែលមានលក្ខណៈបត់បែនគ្រប់គ្រាន់ដើម្បីសម្រួលចំនុចទាំងពីរ។ អ្វីដែលសំខាន់ សហព្រះរាជអាជ្ញាប្រហែលជាខកខានមិនបានបង្ហាញថា តើវានឹងប៉ះពាល់ដោយរបៀបណាដោយការទទួលយកចំនួនឯកសារដ៏កម្រិតដែលដាក់ដោយមេធាវីការពារក្តី ។ ក្នុងការស្វែងការពិត សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូងគប្បីស្វាគមន៍ទទួលយកឯកសារដែលពាក់ព័ន្ធ ជាជាងការខិតខំច្រានចោលឯកសារដោយមូលហេតុបច្ចេកទេសនោះ ។

៥. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងនៅតែបន្តមើលរំលងច្បាប់កម្ពុជាដែលនៅជាធរមាន ហើយងាកទៅរកការអនុវត្តនៅកម្រិតអន្តរជាតិ ដោយមិនសម្លឹងមើលនីតិវិធីជាតិតទៅទៀត នោះអង្គចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងគួរតែកត់សម្គាល់វិធាននីតិវិធី និងភស្តុតាងដែលប្រើនៅតុលាការបណ្តោះអាសន្នដទៃទៀត។ មិនដូចវិធាន ៨៧ ក្រមទាំងនេះដែលអនុញ្ញាតឲ្យជនជាប់ចោទពោលអះអាងការពាររឿងក្តីរបស់គាត់ប្រឆាំងទៅនឹងឯកសារដាក់បន្ទុកដែលលើកឡើងដោយព្រះរាជអាជ្ញា បានដាក់បញ្ចូលវិធីសាស្ត្រទាក់ទងនឹងការបង្ហាញភស្តុតាងដែលស្របគ្នាទាំងស្រុងទៅនឹងយុត្តិសាស្ត្រសិទ្ធិមនុស្ស

ដែលបានលើកយកមកពិភាក្សាខាងលើ[8]។ ត្រង់ចំណុចនេះ មេធាវីការពារក្តីមិនបានដឹងអំពីយុត្តិសាស្ត្រណាមួយនៅលើពិភពលោកដែលតម្រូវឲ្យជនជាប់ចោទដាក់បញ្ជីឯកសារដាច់ស្រេច (ដែលនឹងត្រូវដកចេញជាបន្តបន្ទាប់)ដើម្បីប្រើក្នុងសវនាការជាច្រើនខែនៅមុនពេលដំណើការនីតិវិធីឡើយ។ តាមការអនុវត្តជាក់ស្តែង វិធីសាស្ត្របែបនេះទាំងក្នុងច្បាប់កម្ពុជា ទាំងច្បាប់អន្តរជាតិ គឺមិនអាចអនុវត្តបាន និងមិនមានយុត្តិធម៌ទេ។

៦. នៅទីបញ្ចប់ មុនពេលអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចចុងក្រោយរបស់ខ្លួនទាក់ទងទៅនឹងឯកសារដែលដាក់ដោយមេធាវីការពារក្តីកាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងគួរតែផ្តល់ឱកាសឲ្យមានការពិភាក្សាដោយត្រង់ៗ និងបើកចំហរអំពីភាពពាក់ព័ន្ធរបស់ឯកសារនោះ។ ភាពពាក់ព័ន្ធរបស់ឯកសារជាបញ្ហាស្នូលនៃការពិភាក្សានេះ មិនមែនជាបញ្ហាបច្ចេកទេសដើម្បីឲ្យស្របទៅនឹងកាលកំណត់ដែលបានដាក់កំហិតនោះទេ។ ការច្រានចោលជាមុននូវការពិភាក្សាដោយបើកចំហរទាក់ទងនឹងភាពពាក់ព័ន្ធនៃឯកសារដែលបានស្នើឡើងដោយសារគ្រាន់តែបញ្ហាទាំងនោះ អាចមិនមាននៅក្នុងបញ្ជីដែលបានដាក់ជូនកាលពីលើកមុន វាហាក់បីដូចជាគ្មានបំរើដល់គោលបំណងអ្វី ក្រៅតែពីចង់ចាត់ទុកមេធាវីការពារក្តីដោយអយុត្តិធម៌ និងដោយចេតនាថាជាមនុស្សរឹងរូសមិនស្តាប់បង្គាប់តែប៉ុណ្ណោះ នៅពេលដែលតាមការពិត (និងដូចអ្វីដែលបានគូសបញ្ជាក់ពីខាងលើ) នីតិវិធីកម្ពុជាដែលនៅជាធរមានមិនត្រូវរំលោភនោះ។ ក្នុងករណីណាក៏ដោយការបង្ហាញភស្តុតាង និងការពិភាក្សានៅក្នុងតុលាការ គួរតែជាផ្នែកមួយនៃដំណើរការដែលនាំទៅដល់ការទទួលយក និងការបដិសេធចោលឯកសារ ។ ក្នុងបរិបទនេះ ឯកសារដែលមេធាវីការពារក្តីចង់លើកយកមកបង្ហាញនៅក្នុងតុលាការកាលពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ត្រូវបានភ្ជាប់មកជាមួយក្នុងចម្លើយតបនេះជាមួយរួមជាមួយនឹងការពិពណ៌នាអំពីភាពពាក់ព័ន្ធរបស់វាទៅនឹងសំណុំរឿង ០០២/១[9]។

---

[8] សូមមើល ឧទាហរណ៍, វិធាន៦៥ ស្ទួន(ច) នៃវិធានផ្ទៃក្នុងរបស់តុលាការ ICTY (ដែលតម្រូវឲ្យមេធាវីការពារក្តីដាក់សារណានៅមុនពេលជំនុំជម្រះ *ដែលជាទូទៅ* គូសបញ្ជាក់ពីករណីការពារក្តីយ៉ាងហោចណាស់បីសប្តាហ៍មុនពេលកិច្ច ពិភាក្សាមុនពេលជំនុំជម្រះ) និងវិធាន៦៥(ឆ) (ii) (ដែលតម្រូវឲ្យការដាក់បញ្ជីឈ្មោះសាក្សីរបស់មេធាវីការពារក្តី និងឯកសារ *បន្ទាប់ពី* ការបិទសំណុំរឿងរបស់រដ្ឋអាជ្ញា)។

[9] សូមមើលឧបសម្ព័ន្ធ។

៧. តាមធម្មតា បើពិនិត្យមើលលក្ខខណ្ឌនៃកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អវតក អង្គជំនុំជម្រះសាលាដំបូង អាចអនុវត្តបទដ្ឋានដែលដាក់បញ្ចូលចំណុចល្អបំផុតនៃច្បាប់កម្ពុជាដែលមានស្រាប់ និងបទប្បញ្ញត្តិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតនៅទូទាំងពិភពលោក ។ សង្ឃឹមថាទាក់ទងនឹងបញ្ហាដ៏សំខាន់បំផុតនៃការបង្ហាញភស្តុតាង អវតក នឹងវាយតម្លៃបញ្ហានេះ (ហើយអនុវត្តសេចក្តីសម្រេចរបស់ខ្លួន) ដោយគិតពីផលប្រយោជន៍ស្របច្បាប់នៃក្រុមមេធាវីការពារក្តី ។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE